# ព្រះរាជក្រម

នស/រកម/០៦០៦/០១៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ធានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា ១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា
# ចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីការ
# បំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងកិច្ចព្រមព្រៀងអាស៊ានស្តីពីការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.០២៩ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខ : ៥៦៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

# កិច្ចព្រមព្រៀងអាស៊ាន

## ស្តីពី

# ការបំពុលដោយផ្សែងអ័ព្ទ ឆ្លងកាត់ព្រំដែន

ក្រសួងបរិស្ថាន

2003

# កិច្ចព្រមព្រៀងអាស៊ាន ស្តីពីការបំពុលដោយផ្សែងអព្ទ ឆ្លងកាត់ព្រំដែន

ភាគីទាំងអស់នៅក្នុងកិច្ចព្រមព្រៀងនេះ :

**សូមបញ្ជាក់ឡើងវិញថា** : ការប្តេជ្ញាចិត្តចំពោះបំណងប្រាថ្នារបស់សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (ASEAN) ដូចដែលបានកំណត់នៅក្នុងសេចក្តីប្រកាសទីក្រុងបាងកកចុះថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៦៧ ជាពិសេសដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ីភាគអគ្នេយ៍ នៅក្នុងស្មារតី សមត្ថភាព និងភាពជាដៃគូ និងតាមរយៈនេះដើម្បីចូលរួមចំណែកឆ្ពោះទៅរកសន្តិភាព វឌ្ឍនៈភាព និងវិបុលភាពនៅក្នុងតំបន់ ។

**សូមរំលឹកឡើងវិញថា** : កិច្ចព្រមព្រៀងទីក្រុងកូឡាឡាំពួរ ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានអនុម័តដោយបណ្តារដ្ឋមន្ត្រីបរិស្ថានអាស៊ាន នៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ១៩៩០ ដែលបានអំពាវនាវ ជាអាទិ៍ គឺកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការទប់ស្កាត់ការបំពុលឆ្លងកាត់ព្រំដែន និងការប្រតិបត្តិប្រកបដោយប្រសិទ្ធិភាពខ្ពស់ក្នុងភាពចុះសំរុងគ្នា ។

**សូមរំលឹកឡើងវិញផងដែរថា** :ការអនុម័តនូវផែនការសហប្រតិបត្តិការ ASEAN ឆ្នាំ ១៩៩៥ ស្តីពី ការបំពុលឆ្លងកាត់ព្រំដែនដែលបានបញ្ជាក់យ៉ាងជាក់លាក់ ពីការបំពុលបរិយាកាសឆ្លងកាត់ព្រំដែន និងបានអំពាវនាវជាអាទិ៍គឺការបង្កើតនូវនីតិវិធី និងយន្តការសំរាប់កិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសជាសមាជិក ASEAN ក្នុងការទប់ស្កាត់ និងកាត់បន្ថយភ្លើងឆេះព្រៃនិងផ្សែងអព្ទ ។

**ដោយប្តេជ្ញាចិត្ត** : ដើម្បីផ្តល់ការប្រតិបត្តិចំពោះផែនការសកម្មភាពផ្សែងអព្ទក្នុងតំបន់ឆ្នាំ ១៩៩៧ និងផែនការសកម្មភាព ទីក្រុងហាណូយ ដែលអំពាវនាវអោយធ្វើការអនុវត្តអោយបានពេញលេញចំពោះផែនការសហប្រតិបត្តិការ ASEAN ឆ្នាំ ១៩៩៥ ស្តីពីការបំពុលឆ្លងកាត់ព្រំដែន ដោយសង្កត់ធ្ងន់ជាពិសេសលើផែនការសកម្មភាពផ្សែងអព្ទក្នុងតំបន់អោយសំរេចបាននៅឆ្នាំ ២០០១ ។

**ដោយទទួលស្គាល់ថា** : ជីវិតអាចនឹងទទួលរងឥទ្ធិពលមិនល្អ ដោយការបំពុលដោយផ្សែងអព្ទឆ្លងកាត់ព្រំដែន។

**ដោយក្តីបារម្ភថា** : ការកើនឡើងនៃកំរិតបញ្ចេញសារធាតុបំពុលខ្យល់នៅក្នុងតំបន់ តាមការទាយទុកជាមុនថាអាចនឹងកើនឡើងនូវឥទ្ធិពលមិនល្អបន្ថែមទៀត ។

ដោយទទួលស្គាល់ថា : សេចក្តីត្រូវការដើម្បីធ្វើការសិក្សាពីមូលហេតុ និងទំនាក់ទំនងនៃការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន និងតំរូវការដើម្បីស្វែងរកដំណោះស្រាយសំរាប់បញ្ហាដែលបានកំណត់អត្តសញ្ញាណរួច ។

ស្ទូចបញ្ជាក់ថា : ឆន្ទៈរបស់បណ្តាប្រទេសជាសមាជិក ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត និងដើម្បីបង្កើតគោលនយោបាយថ្នាក់ជាតិសំរាប់ទប់ស្កាត់និងអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

ស្ទូចបញ្ជាក់ផងដែរថា : ឆន្ទៈរបស់បណ្តាប្រទេសជាសមាជិក ដើម្បីធ្វើការសំរបសំរួលសកម្មភាពថ្នាក់ជាតិសំរាប់ទប់ស្កាត់ និងអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន តាមរយៈការផ្លាស់ប្តូរនូវព័ត៌មាន ពិគ្រោះយោបល់ ស្រាវជ្រាវ និងអង្កេតតាមដាន ។

ដោយបំណងប្រាថ្នា : ដើម្បីទទួលធ្វើសកម្មភាពដាច់ពីគ្នា និងរួមគ្នា សំរាប់ធ្វើការវាយតំលៃនូវមូលហេតុដើមប្រភេទ និងវិសាលភាពនៃភ្លើងឆេះព្រៃ និង/រីដីនិងផ្សែងអ័ព្ទតាមរយៈការអនុវត្តនូវគោលនយោបាយ ការប្រតិបត្តិបច្ចេកវិទ្យាបរិស្ថានប្រកបដោយសុវត្ថិភាព និងដើម្បីពង្រឹងសមត្ថភាពថ្នាក់ជាតិ តំបន់ និងកិច្ចសហប្រតិបត្តិការក្នុងការវាយតំលៃ ទប់ស្កាត់ កាត់បន្ថយ និងការគ្រប់គ្រងភ្លើងឆេះព្រៃ និង/រីដី និងផ្សែងអ័ព្ទ ។

ដោយចាំបាច់ថា :គោលនយោបាយដែលត្រូវការជាចំបាច់ ដើម្បីសំរេចបាននូវសកម្មភាពរួមគ្នានេះ គឺ សេចក្តីសំរេច និងការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងនេះ ។

បានយល់ព្រមដូចតទៅ :

## ផ្នែកទី I បទប្បញ្ញត្តិទូទៅ

### មាត្រា ១
### ការប្រើប្រាស់ពាក្យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១ "ភាគីដែលជួយសង្គ្រោះ" មានន័យថា រដ្ឋ អង្គការអន្តរជាតិ អង្គភាពផ្សេងៗ រឺបុគ្គលដែលស្ម័គ្រចិត្តផ្តល់អោយ និង/រឺជួយដល់កិច្ចសង្គ្រោះទៅភាគីដែលស្នើ រឺទទួលនៅក្នុងព្រឹត្តិការណ៍នៃភ្លើងឆេះព្រៃ និង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទ ។

២ "អាជ្ញាធរមានសមត្ថកិច្ច" មានន័យថា អង្គភាពមួយរឺច្រើន ដែលបានជ្រើសតាំង រឺផ្តល់អំណាចដោយភាគីនីមួយៗ ដើម្បីចូលរួមធ្វើសកម្មភាព តំណាងអោយប្រទេសនិមួយៗ ក្នុងការអនុវត្តន៍នូវកិច្ចព្រមព្រៀងនេះ ។

៣ "ការដុតដោយមានការត្រួតពិនិត្យ" មានន័យថា ការដុត ចំហេះ រឺភ្លក់ភ្លើងទាំងឡាយដែលកើតមានឡើងក្នុងទីកន្លែងចំហរ ដែលត្រូវបានត្រួតពិនិត្យតាមរយៈច្បាប់ ការគ្រប់គ្រង បទបញ្ញាតិ រឺគោលការណែនាំនានារបស់ថ្នាក់ជាតិ ហើយនិងមិនបណ្តាលអោយមានអគ្គីភ័យកើតឡើង និងការបំពុលដោយផ្សែងអព្ទ័ឆ្លងកាត់ព្រំដែន ។

៤ "តំបន់ដែលងាយទទួលរងភ្លើងឆេះ" មានន័យថា តំបន់ដែលបានកំណត់ដោយអាជ្ញាធរជាតិ ជាតំបន់ដែលមានភ្លើងឆេះភាគច្រើន ងាយនិងទទួលរងគ្រោះថ្នាក់កើតមានឡើង ។

៥ "ស្ថាប័នទំនាក់ទំនង" មានន័យថា អង្គភាពដែលបានជ្រើសតាំង និងផ្តល់អំណាចដោយភាគីនីមួយៗដើម្បីទទួលនិងបញ្ជូនពត៌មាន និងទិន្នន័យដោយអនុលោមតាមបទបញ្ញាតិនៃកិច្ចព្រមព្រៀងនេះ ។

៦ "ការបំពុលដោយផ្សែងអព្ទ័" មានន័យថា ផ្សែងដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដីដែលបណ្តាលអោយជះឥទ្ធិពលដ៏ធ្ងន់ធ្ងរដល់សុខភាពមនុស្ស មានគ្រោះថ្នាក់ដល់ធនធានដែលមានជីវិត និងប្រពន្ធ័អេកូស៊ីស្តែម និងទ្រព្យសម្បត្តិ និងធ្វើអោយអន់ថយ រឺបង្អាក់ដល់ភាពសុខសាន្ត និងការប្រើប្រាស់ដ៏ត្រឹមត្រូវនូវបរិស្ថានធម្មជាតិ ។

៧ "ភ្លើងឆេះព្រៃ និង/រឺដី" មានន័យថា ការឆេះ ដូចជាឆេះស្រទាប់ធ្យូងថ្ម ការឆេះរុក្ខជាតិពុកផុយ (ជីមមោក) និងការឆេះចំការធំៗ ។

៨ "រដ្ឋជាសមាជិក" មានន័យថា រដ្ឋជាសមាជិក នៃសមាគមប្រជាជាតិអាស៊ីភាគអគ្នេយ៍ ។

៩ "ការដុតនៅទីចំហ" មានន័យថា ការដុត ចំហេះ រឺភ្លក់ភ្លើងទាំងឡាយដែលកើតមានឡើងនៅក្នុងទីចំហ ។

១០ "ភាគី" មានន័យថា រដ្ឋជាសមាជិក ASEAN ដែលយល់ព្រមទទួលអនុវត្តនូវកាតព្វកិច្ចតាមរយៈកិច្ចព្រមព្រៀងនេះ ហើយដែលកិច្ចព្រមព្រៀងនេះចូលជាធរមានចំពោះតែភាគីជាសមាជិក ។

១១ "ភាគីដែលទទួល" មានន័យថា ភាគីដែលយល់ព្រមទទួលយកកិច្ចសង្គ្រោះដែលបានផ្តល់តាមរយៈ ភាគីជំនួយសង្គ្រោះ រឺភាគីផ្សេងទៀត នៅក្នុងព្រឹត្តិការណ៍នៃភ្លើងឆេះព្រៃ និង/រឺដី រឺការបំពុលដោយផ្សែងអព្ទ័ ។

១២ "ភាគីដែលស្នើសុំ" មានន័យថា ភាគីដែលស្នើសុំពីភាគីផ្សេងទៀត រឺភាគីជួយសង្គ្រោះ នៅក្នុងព្រឹត្តិការណ៍នៃភ្លើងឆេះព្រៃ និង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទ ។

១៣ "ការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន" មានន័យថា ការបំពុលដោយផ្សែងអ័ព្ទដែលលក្ខណៈរូបវន្តដើមនៃការបំពុលរបស់វាស្ថិតនៅទាំងមូល រឺជាផ្នែកមួយនៅក្នុងតំបន់ស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងថ្នាក់ជាតិនៃប្រទេសមួយ ហើយដែលផ្សែងអ័ព្ទទាំងនោះត្រូវបានរសាត់ចូលទៅក្នុងតំបន់ស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងនៃប្រទេសដទៃទៀត ។

១៤ "នយោបាយបញ្ឈប់ការដុត" (Zero burning policy) មានន័យថា នយោបាយដែលហាមឃាត់ការដុតនៅទីវាលចំហ ប៉ុន្តែអាចអនុញ្ញាតិអោយដុតដោយមានការត្រួតពិនិត្យក្នុងទំរង់មួយចំនួន ។

## មាត្រា ២

## កម្មវត្ថុ

កម្មវត្ថុនៃកិច្ចព្រមព្រៀងនេះគឺ ដើម្បីទប់ស្កាត់ និងអង្កេតតាមដានការបំពុលដោយផ្សែងអ័ព្ទ ដែលជាលទ្ធផលនៃភ្លើងឆេះព្រៃ និង/រឺដី ហើយត្រូវបានធ្វើការកាត់បន្ថយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាថ្នាក់ជាតិ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ អោយកាន់តែខ្លាំងឡើងថែមទៀត ។ សកម្មភាពទាំងនេះអាចប្រព្រឹត្តទៅនៅក្នុងបរិបទរួមនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៣

## គោលការណ៍

ភាគីទាំងអស់ត្រូវបានណែនាំ តាមរយៈគោលការណ៍មួយចំនួនដូចខាងក្រោម ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ :

១ ដោយអនុលោមទៅតាម ធម្មនុញ្ញអង្គការសហប្រជាជាតិ និងគោលការណ៍នានានៃច្បាប់អន្តរជាតិ ដើម្បីធ្វើអាជីវកម្មលើធនធានរបស់ខ្លួនដែលមាន អោយស្របតាមគោលនយោបាយអភិវឌ្ឍន៍ និងបរិស្ថានរបស់ប្រទេសខ្លួន ហើយនិងការទទួលខុសត្រូវដោយធានាថា រាល់សកម្មភាពទាំងឡាយដែលស្ថិតក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន និងមិនបណ្តាលអោយមានការខូចខាតដល់បរិស្ថាន និងគ្រោះថ្នាក់ដល់

សុខភាពនៅបណ្តាប្រទេសដទៃទៀត រឺក៏នៅក្រៅតំបន់កំណត់នៃដែនសមត្ថកិច្ចគ្រប់គ្រងថ្នាក់ជាតិ ។

២ នៅក្នុងស្មារតីសាមគ្គីភាព និងភាពជាដៃគូរ និងអនុលោមតាម តំរូវការ សមត្ថភាព និងស្ថានភាព របស់ប្រទេសនីមួយៗ ភាគីទាំងអស់ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការ និងសំរបសំរួលដើម្បីទប់ស្កាត់ និងអង្កេតតាមដាន ការបំពុលដោយផ្សែងអព្ភ័ន្តងកាត់ព្រំដែន ដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដី ហើយដែលគ្រោះថ្នាក់ទាំងនេះគួរតែត្រូវបានកាត់បន្ថយ ។

៣ ភាគីទាំងអស់ត្រូវចាត់វិធានការដោយប្រុងប្រយ័ត្នទុកជាមុន ដើម្បីទប់ស្កាត់ និងធ្វើការអង្កេតតាមដានការបំពុលដោយផ្សែងអព្ភ័ន្តងកាត់ព្រំដែនដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដី ហើយដែលត្រូវតែធ្វើការកាត់បន្ថយ និងខិតខំធ្វើអោយស្ថិតនៅក្នុងកំរិតអប្បបរិមាចំពោះឥទ្ធិពលដ៏អាក្រក់របស់វា ។ នៅទីកន្លែងណាមានការគំរាមកំហែងធ្ងន់ធ្ងរ រឺគ្រោះថ្នាក់ដែលពុំអាចកែប្រែបានពីការបំពុលដោយផ្សែងអព្ភ័ន្តងកាត់ព្រំដែន ទោះបីគ្មានវិធីសាស្ត្រតាមបែបវិទ្យាសាស្ត្រក៏ដោយ វិធានការប្រុងប្រយ័ត្នទុកជាមុន គឺជាមធ្យោបាយដ៏ល្អបំផុត ដែលគ្រប់ភាគីជាប់ពាក់ពន្ធ័ទាំងអស់ត្រូវតែទទួលយកទៅអនុវត្ត ។

៤ ភាគីទាំងអស់ត្រូវគ្រប់គ្រងនិងប្រើប្រាស់ធនធានធម្មជាតិរបស់ខ្លួន ដែលរួមមាន ធនធានព្រៃឈើ និងដីប្រកបដោយនិរន្តរភាពនៅក្នុងប្រពន្ធ័អេកូឡូស៊ី ។

៥ ក្នុងការដោះស្រាយការបំពុលដោយផ្សែងអព្ភ័ន្តងកាត់ព្រំដែន ភាគីទាំងអស់ត្រូវធ្វើទំនាក់ទំនងអោយបានសមស្របជាមួយគ្រប់ភាគីជាប់ពាក់ពន្ធ័ រួមមានសហគមន៍មូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល កសិករ និងសហគ្រាសឯកជន ។

## មាត្រា ៤
## ភារកិច្ចទូទៅ

ក្នុងការសំរេចអោយបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ ភាគីទាំងអស់ត្រូវ:

១ ធ្វើសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍ និងប្រតិបត្តិបណ្តាវិធានការនានា ដើម្បីទប់ស្កាត់និងអង្កេតតាមដានការបំពុលដោយ ផ្សែងអព្ភ័ន្តងកាត់ព្រំដែនដែលបណ្តាលមកពីភ្លើងឆេះព្រៃ និង/រឺដី ដែលអគ្គិភ័យទាំងនេះគួរត្រូវបានគេធ្វើការកាត់បន្ថយនិងធ្វើការត្រួតពិនិត្យប្រភពភ្លើងនេះ តាមរយៈការកំណត់អត្តសញ្ញាណនៃអគ្គិភ័យរួមទាំងការអភិវឌ្ឍន៍នូវកម្មវិធីអង្កេតតាមដាន ការវាយតំលៃប្រមាណ និងប្រពន្ធ័ផ្តល់ដំណឹងជាមុន ផ្លាស់ប្តូរពត៌មាននិងបច្ចេកវិទ្យា និងការផ្តល់កិច្ចសង្គ្រោះទៅវិញទៅមក ។

២ នៅពេលណាមានការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែនចាប់ផ្តើមកើតចេញពី ក្នុងដែនដីរបស់ខ្លួនសាមីប្រទេសត្រូវធ្វើការឆ្លើយតបអោយបានឆាប់រហ័សទៅនិងសេចក្តីស្នើសុំរបស់ប្រទេស រឺប្រទេសទាំងឡាយនូវព័ត៌មានដែលពាក់ព័ន្ធ រឺកិច្ចពិគ្រោះយោបល់នានា ដែលជាអគ្គីភ័យទាំងនោះ អាចជះឥទ្ធិពល តាមរយៈការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដោយឈរលើទស្សនៈដើម្បីធ្វើអោយនូវកំរិតទាបបំផុតនូវផលវិបាកទាំងឡាយនៃការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ។

៣ ចាត់វិធានការតាមបែបរដ្ឋបាល បញ្ញត្តិច្បាប់ និង/រឺវិធានការណ៍ដទៃទៀត ដើម្បីអនុវត្តន៍នូវកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ។

## ផ្នែកទី II ការអង្កេតតាមដាន វាយតំលៃ ទប់ស្កាត់ និងការឆ្លើយតប

## មាត្រា ៥

## មជ្ឈមណ្ឌលសំរបសំរួល ASEAN សំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន

១ មជ្ឈមណ្ឌលសំរបសំរួល ASEAN សំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដែលបន្ទាប់ពីពេលនេះតទៅហៅថា មជ្ឈមណ្ឌល ASEAN ត្រូវបានបង្កើតឡើងតាមរយៈនេះ សំរាប់គោលបំណងបង្កលក្ខណៈងាយស្រួលដល់កិច្ចសហប្រតិបត្តិការ និងកិច្ចសំរបសំរួលចំណោមភាគីទាំងអស់ ក្នុងការគ្រប់គ្រងនូវផលប៉ះពាល់នៃភ្លើងឆេះព្រៃនិង/រឺដី ជាពិសេសការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនោះ ។

២ មជ្ឈមណ្ឌល ASEAN ត្រូវធ្វើកិច្ចការលើមូលដ្ឋានដែលថា ដំបូងបង្អស់អាជ្ញាធរជាតិ និងធ្វើសកម្មភាពដើម្បីពន្លត់អគ្គីភ័យ ។ នៅពេលណាអាជ្ញាធរថ្នាក់ជាតិធ្វើការប្រកាសអាសន្ន នោះគេអាចធ្វើការស្នើសុំទៅមជ្ឈមណ្ឌល ASEAN ដើម្បីជួយផ្តល់កិច្ចសង្គ្រោះ ។

៣ គណៈកម្មាធិការមួយដែលបានបង្កើតឡើងមានអ្នកតំណាង អាជ្ញាធរជាតិពីភាគីទាំងអស់និងត្រូវមើលការខុសត្រូវកិច្ចប្រតិបត្តិការនៃមជ្ឈមណ្ឌល ASEAN នេះ ។

៤ មជ្ឈមណ្ឌល ASEAN ត្រូវអនុវត្តន៍ទៅតាមមុខងារដូចបានចែងនៅក្នុងភាពជឧបសម្ព័ន្ធ និងមុខងារដទៃទៀត និងត្រូវតំណាត់ដោយសន្និបាតរបស់ភាគីជាសមាជិក ។

## មាត្រា ៦
## អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នទំនាក់ទំនង

១ ភាគីនីមួយៗត្រូវជ្រើសតាំង អាជ្ញាធរមានសមត្ថកិច្ចមួយរឺច្រើន និងស្ថាប័នទំនាក់ទំនងមួយដែលត្រូវបាន ផ្តល់សិទ្ធអំណាច ដើម្បីធ្វើការងារទាំងនេះជំនួសមុខអោយប្រទេសរបស់ខ្លួន ទៅតាមតំរូវការនៃកិច្ចព្រម ព្រៀងនេះ ។

២ ភាគីនិមួយៗត្រូវជូនដំណឹងដល់ភាគីផ្សេងទៀត និងមជ្ឈមណ្ឌលអាស៊ានអំពី អាជ្ញាធរមានសមត្ថកិច្ច និង ស្ថាប័នទំនាក់ទំនងរបស់ខ្លួន និងបំលាស់ប្តូរផ្សេងៗ នៅក្នុងការជ្រើសតាំងរបស់ខ្លួន ។

៣ មជ្ឈមណ្ឌលអាស៊ាន ត្រូវផ្តល់យ៉ាងទៀងទាត់និងរួសរាន់ដល់ភាគីទាំងអស់ និងអង្គការអន្តរជាតិដែល ទាក់ទងនូវពត៌មាន ដូចបានចែងក្នុងកថាខ័ណ្ឌ២ ខាងលើ ។

## មាត្រា ៧
## ការអង្កេត តាមដាន

១ ភាគីនីមួយៗត្រូវចាត់វិធានការអោយបានសមស្របដើម្បីធ្វើការអង្កេតតាមដាននូវ :

ក-គ្រប់តំបន់ដែលងាយនិងទទួលរងភ្លើងឆេះ

ខ-រាល់ទីកន្លែងដែលមានភ្លើងឆេះព្រៃនិង/ដី

គ-រាល់ស្ថានភាពបរិស្ថានដែលនាំអោយមាននូវ ភ្លើងឆេះព្រៃ និង/រឺដី ទាំងនោះ និង

ឃ- ការបំពុលដោយផ្សែងអ័ព្ទ ដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដីទាំងនោះ ។

២ ភាគីនីមួយៗ ត្រូវជ្រើសតាំងអង្គភាពមួយរឺច្រើន ដើម្បីបំពេញមុខងារជាមជ្ឈមណ្ឌលធ្វើការអង្កេតតាម ដាន ថ្នាក់ជាតិ ដើម្បីទទួលរ៉ាប់រងធ្វើការអង្កេតតាមដានដូចបានចែងក្នុងកថាខ័ណ្ឌ១ខាងលើ ដោយអនុ លោមតាមទំរង់ការថ្នាក់ជាតិរៀងៗខ្លួន ។

៣ ក្នុងព្រឹត្តការណ៍មានអគ្គីភ័យកើតឡើង ភាគីទាំងអស់ត្រូវចាប់ផ្តើមធ្វើសកម្មភាពជាបន្ទាន់ដើម្បីត្រួតពិនិត្យ រឺធ្វើការពន្លត់ភ្លើងទាំងនោះ ។

## មាត្រា ៨
## ការវាយតំលៃ

១ ភាគីនីមួយៗត្រូវធានាថា មជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិយល់ព្រមផ្តល់យ៉ាងទៀងទាត់ និងធ្វើការប្រាស្រ័យទាក់ទងដល់មជ្ឈមណ្ឌលអាស៊ានដោយផ្ទាល់ រឺតាមរយៈស្ថាប័នទំនាក់ទំនងរបស់ខ្លួន នូវទិន្នន័យដែលទទួលបានទាក់ទងទៅនឹងភ្លើងឆេះ តំបន់ដែលងាយទទួលរងគ្រោះភ្លើងឆេះព្រៃ និង/រឺដី រាល់ស្ថានភាពបរិស្ថានដែលនាំអោយមានភ្លើងឆេះព្រៃនិង/រឺដី និងការបំពុលដោយផ្សែងអព្ទដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដីទាំងនោះ ។

២ មជ្ឈមណ្ឌលអាស៊ានត្រូវទទួលធ្វើការប្រមូលផ្តុំនិងវិភាគ នូវទិន្នន័យដែលបានប្រាស្រ័យទាក់ទង តាមរយៈមជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិ រឺស្ថាប័នទំនាក់ទំនង ។

៣ លើមូលដ្ឋាននៃការវិភាគទិន្នន័យដែលទទួលបានទាំងនេះ មជ្ឈមណ្ឌលអាស៊ានត្រូវផ្តល់ជូនវិញទៅភាគីនីមួយៗតាមវិធីណាដែលអាចធ្វើបាន នូវការវាយតំលៃនៃភាពគ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាពមនុស្ស រឺបរិស្ថានដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដី និងដែលបណ្តាលអោយមានការបំពុលដោយផ្សែងអព្ទឆ្លងកាត់ព្រំដែន ។

## មាត្រា ៩
## វិធានការទប់ស្កាត់

ភាគីនីមួយៗ ត្រូវទទួលយកនូវវិធានការដើម្បីទប់ស្កាត់ និងត្រួតពិនិត្យនូវសកម្មភាពទាំងអស់ដែលទាក់ទងនិងភ្លើងឆេះព្រៃនិង/រឺដី ដែលអគ្គីភ័យទាំងនេះអាចនាំដល់ការបំពុលដោយផ្សែងអព្ទឆ្លងកាត់ព្រំដែន បណ្តាវិធានការទាំងនោះរួមមាន :

ក- ការអភិវឌ្ឍន៍ និងប្រតិបត្តិវិធានការច្បាប់ និងបទបញ្ញត្តិផ្សេងៗ មានដូចជាកម្មវិធី និងយុទ្ធសាស្ត្រនានា ដើម្បីលើកកំពស់គោលនយោបាយបញ្ឈប់ការដុតនៅទីចំហ ដើម្បីដោះស្រាយភ្លើងឆេះព្រៃ និង/រឺដី ដែលបណ្តាលអោយមានការបំពុលដោយផ្សែងអព្ទឆ្លងកាត់ព្រំដែន ។

ខ- ការអភិវឌ្ឍន៍គោលនយោបាយនានា អោយបានសមស្របដើម្បីបានាទប់ទល់នូវគ្រប់សកម្មភាពដែលអាចនាំទៅរកភ្លើងឆេះព្រៃនិង/រឺដី ។

គ- កំណត់មុខសញ្ញាណនិងធ្វើការអង្កេតតាមដានតំបន់ដែលងាយទទួលរងភ្លើងឆេះ ដែលនាំអោយកើតមានឡើងនូវភ្លើងឆេះព្រៃនិង/រឺដី ។

ឃ- ពង្រឹងការគ្រប់គ្រងអគ្គីភ័យនៅមូលដ្ឋាន និងសមត្ថភាពប្រយុទ្ធប្រឆាំងអគ្គីភ័យ និងការសំរបសំរួល ដើម្បីទប់ស្កាត់ការកើតមានឡើងនូវភ្លើងឆេះព្រៃនិង/រឺដី ។

ង- លើកកំពស់ការអប់រំសាធារណៈ និងយុទ្ធនាការបង្កើតនូវចំណេះដឹង និងពង្រឹងការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងអគ្គីភ័យ ដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃនិង/រឺដី និងការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែនដែលកើតពីអគ្គីភ័យទាំងនោះ ។

ច- លើកកំពស់ និងប្រើប្រាស់នូវចំណេះ ដឹងនិងយកបទពិសោធន៍ដែលមានក្នុងការទប់ស្កាត់ និងការគ្រប់គ្រងអគ្គីភ័យនិង

ឆ- ធ្វើអោយប្រាកដថា រាល់វិធានការច្បាប់ រដ្ឋបាល និងវិធានការដទៃទៀតត្រូវបានអនុវត្តដើម្បីត្រួតពិនិត្យការដុតនៅទីចំហ និងទប់ស្កាត់ការត្រួសត្រាយព្រៃដោយប្រើប្រាស់ភ្លើង ។

## មាត្រា ១០
## ការប្រុងប្រៀបទុកជាមុន

១- ភាគីទាំងអស់ត្រូវបង្កើតឡើងដោយរួមគ្នា រឺផ្ទាល់ខ្លួននូវយុទ្ធសាស្ត្រ និងផែនការទប់ទល់ ដើម្បីកំណត់ គ្រប់គ្រង និងត្រួតពិនិត្យនូវភាពគ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាពមនុស្ស និងបរិស្ថានដែលកើតចេញពីភ្លើងឆេះព្រៃ និង/រឺដី និងការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនោះ ។

២- ភាគីទាំងអស់ត្រូវរៀបចំអោយបានសមស្របនូវបែបបទសំរាប់ធ្វើប្រតិបត្តិការដែលមានលក្ខណៈជាខ្នាតគំរូរួម សំរាប់កិច្ចសហប្រតិបត្តិការតំបន់ និងសកម្មភាពថ្នាក់ជាតិដែលបានតំរូវក្រោមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១១
## ការឆ្លើយតបបន្ទាន់របស់ថ្នាក់ជាតិ

១- ភាគីនីមួយៗ ត្រូវធ្វើអោយប្រាកដថា រាល់វិធានការសមស្របផ្នែកច្បាប់ រដ្ឋបាល និងថវិកា ត្រូវបានគេអនុវត្ត ដោយធ្វើការប្រមូលផ្តុំនូវធនធានដែលមាន ដូចជា គ្រឿងបរិក្ខារ សំភារៈ ធនធានមនុស្ស

និងធនធានថវិកា ដែលត្រូវការចាំបាច់សំរាប់ឆ្លើយតប និងកាត់បន្ថយផលប៉ះពាល់ដោយភ្លើងឆេះព្រៃ និង/រឺផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនោះ ។

២- ភាគីនីមួយៗ ត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីផ្សេងទៀតនិងមជ្ឈមណ្ឌលអាស៊ាននូវវិធានការទាំងនេះ ។

## មាត្រា ១២
## ការឆ្លើយតបបន្ទាន់រួមគ្នាតាមរយៈការផ្តល់ជំនួយសង្គ្រោះ

១- ប្រសិនបើភាគីណាមួយត្រូវការកិច្ចជំនួយសង្គ្រោះ នៅក្នុងព្រឹត្តការណ៍ភ្លើងឆេះព្រៃនិង/រឺ រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យនៅក្នុងដែនដីរបស់ខ្លួននោះគេអាចធ្វើការស្នើសុំជំនួយសង្គ្រោះពីភាគីផ្សេងទៀត ដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌលអាស៊ាន រឺប្រទេស រឺអង្គការអន្តរជាតិដទៃទៀត ។

២- កិច្ចការជួយសង្គ្រោះនេះអាចត្រូវបានអោយមកបំរើការនៅពេលមានសំណើយល់ព្រមពីភាគីដែលស្នើសុំ រឺក៏នៅពេលណាមានការផ្តល់ជូនដោយស្ម័គ្រចិត្តពីភាគីដទៃទៀតនោះក៏ត្រូវមានការយល់ព្រមពីភាគីម្ចាស់ផ្ទះផងដែរ ។

៣- ភាគីនីមួយៗ ត្រូវធ្វើការសំរេចចិត្ត និងជូនដំណឹងអោយបានឆាប់រហ័សដល់ភាគីដែលត្រូវស្នើសុំដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌលអាស៊ាន ចំពោះសំណើសុំកិច្ចជួយសង្គ្រោះ អោយបានច្បាស់លាស់ ថាតើគេអាចផ្តល់នូវកិច្ចជួយសង្គ្រោះដែលបានស្នើបែបណា ពីទំហំ និងលក្ខខណ្ឌនៃការជួយសង្គ្រោះទាំងនោះ ។

៤- ភាគីនីមួយៗ ត្រូវធ្វើសេចក្តីសំរេចចិត្ត និងជូនដំណឹងអោយបានឆាប់រហ័សដល់ភាគីដែលជួយដោយផ្ទាល់ រឺតាមរយៈមជ្ឈមណ្ឌលអាស៊ាន ចំពោះការផ្តល់ជូន ការជួយសង្គ្រោះអោយបានច្បាស់លាស់ ថាតើគេអាចទទួលយកនូវជំនួយសង្គ្រោះដែលផ្តល់អោយឬទេ និងទំហំនិងលក្ខខណ្ឌនៃការជួយសង្គ្រោះទាំងនោះ ។

៥- ភាគីដែលស្នើ ត្រូវបញ្ជាក់អោយបានច្បាស់នូវទំហំ និងប្រភេទនៃជំនួយសង្គ្រោះដែលត្រូវការ និងទីកន្លែងធ្វើសកម្មភាព និងត្រូវផ្តល់ជូនភាគីដែលត្រូវជួយ ដោយភ្ជាប់ជាមួយនិងពត៌មានដែលចាំបាច់ សំរាប់ធ្វើការកំណត់នូវវិសាលភាពដើម្បីអោយជំនួយសង្គ្រោះអាចឆ្លើយតបទៅនិងសេចក្តីស្នើសុំ ។ ក្នុងគ្រាដែលពុំអាចនិងធ្វើទៅបានរបស់ភាគីដែលស្នើសុំក្នុងការបញ្ជាក់អោយបានច្បាស់លាស់ពីទំហំ និងប្រភេទនៃជំនួយសង្គ្រោះដែលត្រូវការនោះភាគីដែលស្នើសុំ និងភាគីដែលជួយសង្គ្រោះត្រូវធ្វើការចាត់ប្រមាណ និងសំរេចចិត្តរួមគ្នាទៅលើទំហំនិងប្រភេទជំនួយសង្គ្រោះដែលត្រូវការខាងលើ ។

៦- ភាគីទាំងអស់ត្រូវធ្វើការបញ្ជាក់ និងជំរាបជូនមជ្ឈមណ្ឌលអាស៊ាន នូវអ្នកជំនាញការគ្រឿងបរិក្ខារ សំភារៈ ដែលអាចរកបានក្នុងកំរិតសមត្ថភាពរបស់ខ្លួន សំរាប់ផ្តល់ជំនួយសង្គ្រោះទៅអោយភាគីផ្សេងទៀត ក្នុងគ្រាដែលមានភ្លើងឆេះព្រៃនិង/ឬដី ឬ ការបំពុលដោយផ្សែងអ័ព្ទដែលអាចបណ្តាលមកពីអគ្គិភ័យ ក៏ដូច ជាលក្ខខណ្ឌមួយចំនួនទៀត ជាពិសេសថវិកាអាចនិងផ្តល់ជូនក្រោមជំនួយសង្គ្រោះ ។

## មាត្រា ១៣
## ការចាត់ចែង និងត្រួតពិនិត្យជំនួយសង្គ្រោះ

លើកលែងតែមានការយល់ព្រមផ្សេងទៀត :

១- ភាគីដែលស្នើសុំ ឬទទួល ត្រូវធ្វើការហាត់ហ្វឹកហ្វឺន ពីការចាត់ចែង ត្រួតពិនិត្យ សំរបសំរួល និងការត្រួតត្រា មើលនូវជំនួយសង្គ្រោះទៅក្នុងដែនដីខ្លួន ។ នៅទីកន្លែងណាដែលជំនួយសង្គ្រោះមានជាប់ពាក់ព័ន្ធដល់ បុគ្គលិក ភាគីដែលជួយសង្គ្រោះ ដោយមានកិច្ចពិគ្រោះយោបល់ជាមួយភាគីដែលស្នើសុំ ឬទទួលត្រូវចាត់ តាំងបុគ្គលិក ឬគ្រឿងបរិក្ខារដែលផ្តល់ដោយភាគីរបស់ខ្លួន ។ បុគ្គល ឬអង្គភាពដែលបានចាត់តាំងហើយ ត្រូវធ្វើការហាត់ហ្វឹកហ្វឺន ការត្រួតត្រាមើលដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីដែល ស្នើសុំ ឬទទួល ។

២- ភាគីដែលស្នើសុំ ឬទទួល ត្រូវផ្តល់ជូននូវគ្រឿងបរិក្ខារ និងសេវាកម្មផ្សេងៗ ក្នុងស្រុកសំរាប់ចាត់ចែង ការងារកិច្ចជួយសង្គ្រោះអោយបានល្អ និងមានប្រសិទ្ធិភាព ។ ហើយក៏ត្រូវធ្វើអោយប្រាកដផងដែរដល់កិច្ច ការពារបុគ្គលិក គ្រឿងបរិការ និងសំភារៈផ្សេងៗ ដែលនាំចូលមកក្នុងទឹកដីរបស់ខ្លួនដោយ ឬក្នុងនាមនៃ ភាគីដែលជួយសង្គ្រោះ សំរាប់គោលបំណងទាំងនេះ ។

៣- ភាគីដែលផ្តល់ ឬទទួលជំនួយសង្គ្រោះ ដោយឆ្លើយតបទៅតាមសំណើដូចមានចែងក្នុងកថាខ័ណ្ឌ ១ ខាងលើ ត្រូវធ្វើការសំរបសំរួលអោយបានល្អប្រសើរ ជំនួយសង្គ្រោះទាំងនោះទៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ១៤
## ករណីលើកលែង និងការជួយសំរួលចំពោះការផ្តល់ជំនួយសង្គ្រោះ

១- ភាគីដែលស្នើសុំ ឬទទួល ត្រូវអនុញ្ញាតិអោយបុគ្គលិករបស់ភាគីដែលជួយសង្គ្រោះ និងបុគ្គលិកដែលធ្វើ កិច្ចការជំនួសមុខអោយភាគីខ្លួន នូវករណីលើកលែងនានាដែលចាំបាច់ និងការបង្កលក្ខណៈងាយស្រួល ដល់ការបំពេញភារកិច្ចរបស់ពួកគេ ។

២- ភាគីដែលស្នើសុំ រឺទទួលត្រូវអនុញ្ញាតិអោយភាគីដែលជួយសង្គ្រោះ នូវការអោយរួចពន្ធនានា រឺការបង់ថ្លៃផ្សេងៗទៀត លើគ្រឿងបរិក្ខារ និងសំភារៈដែលនាំចូលមកក្នុងដែនដីនៃប្រទេសដែលស្នើសុំ រឺទទួល សំរាប់គោលបំណងនៃការជួយសង្គ្រោះ ។

៣- ភាគីដែលស្នើសុំ រឺទទួល ត្រូវបង្កលក្ខណៈងាយស្រួលដល់ការចូលស្នាក់នៅ និងចេញពីដែនដីរបស់ខ្លួន ចំពោះបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈនានា ដែលពាក់ព័ន្ធ រឺប្រើប្រាស់នៅក្នុងការជួយសង្គ្រោះ ។

## មាត្រា ១៥
## ការឆ្លងកាត់នៃបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈនានា ចំពោះការផ្តល់ជំនួយសង្គ្រោះ

ផ្អែកតាមសំណើនៃភាគីដែលពាក់ព័ន្ធ ភាគីនិមួយៗត្រូវស្នើបង្កលក្ខណៈងាយស្រួលដល់ការឆ្លងកាត់តាមរយៈទឹកដីរបស់ខ្លួនដោយមានការជូនដំណឹងត្រឹមត្រូវនូវបុគ្គលិក គ្រឿងបរិក្ខារ និងសំភារៈនានាដែលពាក់ព័ន្ធ រឺប្រើប្រាស់នៅក្នុងការជួយសង្គ្រោះ ដល់ភាគីដែលស្នើសុំ រឺទទួល ។

## ផ្នែកទី III
## កិច្ចសហប្រតិបត្តិការ ផ្នែកបច្ចេកទេសនិងការស្រាវជ្រាវវិទ្យាសាស្ត្រ

## មាត្រា ១៦
## កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស

១- ដើម្បីបង្កើនការប្រុងប្រៀបទុកជាមុន និងកាត់បន្ថយភាពដែលអាចមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងបរិស្ថានដែលកើតចេញពីភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះ ភាគីទាំងអស់ត្រូវទទួលធ្វើកិច្ចសហប្រតិបត្តិការ នៅក្នុងវិស័យនេះ រួមមានដូចតទៅ :

ក- សំរួលដល់ការប្រមូលផ្តុំនូវធនធានអោយបានសមស្របទាំងខាងក្នុង និងខាងក្រៅភាគីទាំងអស់ ។

ខ- លើកកំពស់ការធ្វើអោយមានគំរូខ្នាតឯកភាពគ្នានៃទំរង់របាយការណ៍ ទិន្នន័យ និងពត៌មាន ។

គ- លើកកំពស់ ការផ្លាស់ប្តូរ ពត៌មាន ជំនាញការ បច្ចេកវិទ្យា យុទ្ធវិធី និងមុខជំនាញដែលពាក់ព័ន្ធ ។

ឃ- ផ្តល់ រឺធ្វើការរៀបចំវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ មានការអប់រំនិងយុទ្ធនាការផ្សព្វផ្សាយចំណេះដឹងជាពិសេស ទាក់ទងទៅនិងការជំរុញការអនុវត្តនីតិវិធានការបញ្ឈប់ការដុត (Zero-burning) និងផលប៉ះពាល់នៃការបំពុលដោយផ្សែងអព្ទ ទៅលើសុខភាពមនុស្សនិងបរិស្ថាន ។

ង- ធ្វើការអភិវឌ្ឍន៍ រឺបង្កើតឡើងនូវយុទ្ធវិធីស្តីពីការដុតដោយមានការត្រួតពិនិត្យជាពិសេស អ្នកធ្វើកសិកម្មពនេចរ និងម្ចាស់កសិដ្ឋានតូចៗ ដើម្បីធ្វើការផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍លើការអនុវត្តន៍ទាំងនោះ ។

ច- សំរបសំរួលដល់ការផ្លាស់ប្តូរបទពិសោធន៍ និងពត៌មានទាក់ទងក្នុងចំណោមអាជ្ញាធរអនុវត្ត នៃភាគីទាំងអស់ ។

ឆ- លើកកំពស់ និងធ្វើការអភិវឌ្ឍន៍ទីផ្សារ សំរាប់ការយកមកប្រើប្រាស់នូវជីវៈម៉ាស់ និងវិធីសាស្ត្រសមស្របសំរាប់ការចាក់ចោលនូវសំណល់កសិកម្ម ។

ជ- ធ្វើការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល ដល់ក្រុមអន្តរាគមន៍អគ្គីភ័យ និងគ្រូបង្គោល ដើម្បីអោយពួកគេអាចធ្វើការបណ្តុះបណ្តាលនៅឯមូលដ្ឋាន កំរិតជាតិ កំរិតតំបន់ និង

ឈ- ពង្រឹង និងធ្វើអោយប្រសើរឡើងនូវសមត្ថភាពបច្ចេកទេសនៃភាគីទាំងអស់ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

២- មជ្ឈមណ្ឌលអាស៊ានត្រូវធ្វើការសំរបសំរួលសកម្មភាព សំរាប់កិច្ចសហប្រតិបត្តិការដូចដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ ខាងលើ ។

## មាត្រា ១៧
## ការស្រាវជ្រាវវិទ្យាសាស្ត្រ

ភាគីទាំងអស់ត្រូវលើកកំពស់ និងគាំទ្រដោយរួមគ្នា រឺផ្ទាល់ខ្លួន នៅពេលណាដែលអាចធ្វើបាន រួមមាន កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ លើផ្នែកកម្មវិធីស្រាវជ្រាវ វិទ្យាសាស្ត្រ និងបច្ចេកទេស ដែលទាក់ទងដល់ឫសគល់ និងផលវិបាកទាំងឡាយនៃការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន និងមធ្យោបាយ វិធីសាស្ត្រ គ្រឿងបរិក្ខារ សំរាប់គ្រប់គ្រងភ្លើងឆេះព្រៃនិង/រឺដី រួមទាំងការពន្លត់អគ្គីភ័យ ។

# ផ្នែក IV ការរៀបចំស្ថាប័ន

## មាត្រា ១៨
## សន្និបាតភាគី

១- សន្និបាតភាគីត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងនេះ ។ សម័យប្រជុំដំបូងនៃសន្និបាតភាគី ត្រូវបានរៀបចំឡើងដោយលេខាធិការដ្ឋានមិនលើសពីរយៈពេល ១ឆ្នាំ ក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរ

មាន ។ បន្ទាប់មកសម័យប្រជុំសាមញ្ញានៃសន្និបាតភាគី និងត្រូវប្រារព្ធយ៉ាងតិច ១ ដងជារៀងរាល់ឆ្នាំ តាមតែអាចធ្វើទៅបាន ក្នុងពេលជាមួយគ្នា និងកិច្ចប្រជុំនានារបស់អាស៊ាន ។

២- សម័យប្រជុំវិសាមញ្ញ និងត្រូវប្រារព្ធឡើង នៅពេលវេលាផ្សេងទៀតពីខាងលើ នៅពេលមានសំណើពីភាគីមួយ ហើយដែលសំណើនោះត្រូវបានគាំទ្រដោយភាគីយ៉ាងតិចមួយផ្សេងទៀត ។

៣- សន្និបាតភាគីត្រូវ រក្សាទុកការត្រួតពិនិត្យឡើងវិញបន្ត និងការវាយតំលៃនូវកិច្ចព្រមព្រៀងនេះ និងនៅទីបញ្ចប់ត្រូវ :

ក- ចាត់ទុកសកម្មភាពទាំងនេះជាការចាំបាច់ ដើម្បីធ្វើអោយប្រាកដនូវការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងនេះ ។

ខ- ពិនិត្យពិចារណាលើរបាយការណ៍នានា និងពត៌មានផ្សេងៗទៀត ដែលបានស្នើឡើងពីភាគីមួយ ដោយផ្ទាល់ រឺតាមរយៈលេខាធិការដ្ឋាន ។

គ- ពិនិត្យពិចារណា និងអនុមត័លើពិធីសារនានា ដោយអនុលោមតាមមាត្រា២១នៃកិច្ចព្រមព្រៀងនេះ ។

ឃ- អនុមត័ ត្រួតពិនិត្យឡើងវិញ និងកែសំរួល តារាឧបសម្ព័ន្ធនានា ចំពោះកិច្ចព្រមព្រៀងនេះ ។

ង- បង្កើតឡើងនូវក្រុមការងារមួយចំនួនទៅតាមតំរូវការសំរាប់អនុវត្តកិច្ចព្រមព្រៀងនេះ និង

ច- ពិនិត្យពិចារណា និងទទួលយកនូវសកម្មភាពនានា បន្ថែមទៀតដែលតំរូវសំរាប់សំរេចអោយបាននូវកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ១៩

## លេខាធិការដ្ឋាន

១- តាមរយៈនេះ លេខាធិការដ្ឋានមួយត្រូវបានបង្កើតឡើង

២- មុខងារនៃលេខាធិការដ្ឋាននេះត្រូវរួមបញ្ចូល

ក- រៀបចំចាត់ចែងដំណើរការកិច្ចប្រជុំសន្និបាតភាគី និងក្រុមការងារផ្សេងទៀត ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងនេះ ។

ខ- បញ្ជូនទៅគ្រប់ភាគី នូវសេចក្តីជូនដំណឹង របាយការណ៍ និងពត៌មានផ្សេងៗទៀតដែលទទួលបានដោយ អនុលោមតាមកិច្ចព្រមព្រៀងនេះ ។

គ- ទទួលយកមកពិនិត្យនូវពត៌មាន និងការស៊ើបអង្កេតនានាពីភាគីទាំងអស់ និងធ្វើការពិគ្រោះយោបល់ជាមួយពួកគេ លើសំណើផ្សេងៗ ដែលទាក់ទងដល់កិច្ចព្រមព្រៀងនេះ ។

ឃ- ធ្វើអោយប្រាកដនូវការសំរបសំរួលដែលចាំបាច់ ជាមួយអង្គការអន្តរជាតិផ្សេងៗទៀតដែលពាក់ព័ន្ធ និងជាពិសេសការរៀបចំចាត់ចែងទៅតាមសេចក្តីត្រូវការសំរាប់បំពេញកិច្ចការអោយមានប្រសិទ្ធិភាពដល់មុខងាររបស់លេខាធិការដ្ឋាន ។

ង- បំពេញការងារផ្សេងៗ ទៀតទៅតាមការផ្តល់អោយពីភាគីទាំងអស់ ។

៣- លេខាធិការដ្ឋានអាស៊ាន ត្រូវបំរើការងារ ជាលេខាធិការដ្ឋាននៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២០
## ការចាត់ចែងគ្រប់គ្រង មូលនិធិ

១- តាមរយៈនេះ មូលនិធិ សំរាប់អនុវត្តកិច្ចព្រមព្រៀងនេះត្រូវបានបង្កើតឡើង ។

២- មូលនិធិនេះ ត្រូវបានគេស្គាល់ថាជាមូលនិធិសំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអព្ទ័ឆ្លងកាត់ព្រំដែន ។

៣- មូលនិធិនេះ និងត្រូវចាត់ចែងគ្រប់គ្រងដោយលេខាធិការដ្ឋានអាស៊ាន ក្រោមការណែនាំពីសន្និបាតរបស់ភាគី ។

៤- ភាគីទាំងអស់ត្រូវបង់វិភាគទានដោយស្ម័គ្រចិត្តទៅមូលនិធិនេះ ដោយអនុលោមតាមសេចក្តីសំរេចនៃសន្និបាតភាគី ។

៥- មូលនិធិនេះ ត្រូវបានបើកចំហរចំពោះវិភាគទានដែលបានមកពីប្រភពផ្សេងៗទៀត ហើយដែលត្រូវទទួលការយល់ស្របរឺការយល់ព្រម ដោយភាគីទាំងអស់ ។

៦- ភាគីទាំងអស់អាចយកមកប្រើប្រាស់នូវធនធានបន្ថែមដែលត្រូវការ នៅទីកន្លែងណាដែលចាំបាច់ សំរាប់អនុវត្តនូវកិច្ចព្រមព្រៀងនេះ ពីអង្គការអន្តរជាតិនានា ដែលពាក់ព័ន្ធ ជាពិសេសស្ថាប័នមូលនិធិក្នុងតំបន់ និងសហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ ។

## ផ្នែក V នីតិវិធីផ្សេងៗ

### មាត្រា ២១
### ពិធីសារនានា

១- ភាគីទាំងអស់ត្រូវធ្វើកិច្ចសហប្រតិបត្តិការនៅក្នុងការរៀបចំ និងការយល់ព្រមនូវពិធីសារនានាចំពោះ កិច្ចព្រមព្រៀងនេះ ដោយដាក់បញ្ចូលនូវវិធានការនានា ដែលបានព្រមព្រៀងគ្នា ដូចជា ទំរង់ការ និងបទដ្ឋានតំរូវសំរាប់អនុវត្តកិច្ចព្រមព្រៀងនេះ ។

២- សន្និបាតភាគីអាច ធ្វើការអនុម័តលើពិធីសារនានានៃកិច្ចព្រមព្រៀងនេះនៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំដោយមតិឯកភាពទូទៅនៃគ្រប់ភាគី ។

៣- អត្ថបទនៃពិធីសារដែលបានស្នើឡើងត្រូវបានគេធ្វើការ ទាក់ទងទៅគ្រប់ភាគីតាមរយៈលេខាធិការដ្ឋានយ៉ាងតិច ៦ ខែមុនការប្រជុំ ។ សេចក្តីត្រូវការសំរាប់អោយពិធីសារចូលជាធរមានត្រូវបង្កើតឡើងតាមរយៈបញ្ញត្តិនៃពិធីសារនេះ ។

### មាត្រា ២២
### ការធ្វើវិសោធនកម្មចំពោះកិច្ចព្រមព្រៀង

១- ភាគីទាំងឡាយអាចស្នើសុំវិសោធនកម្មចំពោះកិច្ចព្រមព្រៀងនេះបាន ។

២- អត្ថបទវិសោធនកម្មទាំងឡាយ ដែលបានស្នើសុំត្រូវបានគេធ្វើការទាក់ទងទៅគ្រប់ភាគីតាមរយៈលេខាធិការដ្ឋានយ៉ាងតិច ៦ ខែមុនការប្រជុំសន្និបាតភាគីដែលនៅឯសម័យប្រជុំនោះ ត្រូវបានគេស្នើសុំអោយធ្វើការអនុម័តលើសំណើវិសោធនកម្មទាំងនោះ ។ លេខាធិការដ្ឋាន ត្រូវធ្វើទំនាក់ទំនងផងដែរចំពោះភាគីចុះហត្ថលេខានៃកិច្ចព្រមព្រៀងលើសេចក្តីស្នើសុំវិសោធនកម្មនេះ ។

៣- វិសោធនកម្មទាំងឡាយនឹងត្រូវបានអនុម័ត ដោយមតិឯកភាពទូទៅ នៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំនៃសន្និបាតភាគី ។

៤- វិសោធនកម្មទាំងឡាយ ចំពោះកិច្ចព្រមព្រៀងនេះនឹងត្រូវបានដាក់អោយនៅក្រោមការទទួលស្គាល់ពីគ្រប់ភាគី ។ កន្លែងដកល់ឯកសារ និងត្រូវចែកជូននូវវិសោធនកម្មដែលបានអនុម័តរួចទៅគ្រប់ភាគីសំរាប់សុំការ

ទទួលស្គាល់ ។ វិសោធនកម្មនេះ នឹងត្រូវចូលជាធរមានរយៈពេល ៣០ថ្ងៃបន្ទាប់ពីបានបញ្ជូនដល់កន្លែងដាក់តំកល់ឯកសារ ហើយដែលបានទទួលស្គាល់ពីគ្រប់ភាគី ។

៥- ក្រោយពេលចូលជាធរមាននៃវិសោធនកម្ម ចំពោះកិច្ចព្រមព្រៀងនេះ ភាគីថ្មីផ្សេងទៀតនឹងត្រូវក្លាយជាភាគីមួយចំពោះ កិច្ចព្រមព្រៀងនេះដូចដែលបានធ្វើវិសោធនកម្មរួច ។

## មាត្រា ២៣

## ការអនុម័ត និងការធ្វើវិសោធនកម្ម ឧបសម្ព័ន្ធ

១- ឧបសម្ព័ន្ធនានាភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនេះ បង្កើតបានជាផ្នែកមួយដែលជាបតិដ្ឋាប័ន នៃកិច្ចព្រមព្រៀងនេះ និងដរាបណាពុំមានការបញ្ជាក់ផ្សេងទៀតទេនោះ ឯកសារយោងភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនោះរួមបញ្ចូលគ្នា ក្នុងពេលតែមួយ ទៅនឹងឯកសារយោង ឧបសម្ព័ន្ធដែលមាននោះ ។

២- ឧបសម្ព័ន្ធនានាត្រូវបានគេអនុម័ត ដោយមតិឯកភាពទូទៅ នៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំ នៃសន្និបាតភាគី ។

៣- ភាគីនានាអាចស្នើធ្វើវិសោធនកម្មទៅលើឧបសម្ព័ន្ធបាន ។

៤- វិសោធនកម្មទៅនឹងឧបសម្ព័ន្ធ ត្រូវបានគេអនុម័ត ដោយមតិឯកភាពទូទៅនៅឯសម័យប្រជុំសាមញ្ញប្រចាំឆ្នាំនៃសន្និបាតភាគី ។

៥- ឧបសម្ព័ន្ធភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងនេះ និងវិសោធនកម្មទៅលើឧបសម្ព័ន្ធនានានឹងត្រូវដាក់អោយនៅក្រោមការទទួលស្គាល់ពីគ្រប់ភាគី ។ កន្លែងដាក់តំកល់ឯកសារ និងត្រូវចែកជូននូវឧបសម្ព័ន្ធ រឺវិសោធនកម្មទៅលើឧបសម្ព័ន្ធដែលបានអនុម័តរួចទៅគ្រប់ភាគី សំរាប់សុំការទទួលស្គាល់ ។ ឧបសម្ព័ន្ធរឺវិសោធនកម្មទៅលើឧបសម្ព័ន្ធត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីបានបញ្ជូនដល់កន្លែងតំកល់ឯកសារ ហើយដែលបានទទួលស្គាល់ពីគ្រប់ភាគី ។

## មាត្រា ២៤
## និតិវិធី និងបែបបទហិរញ្ញវត្ថុ

សម័យប្រជុំលើកដំបូងរបស់សន្និបាតភាគី ត្រូវអនុម័តដោយមតិឯកភាពទូទៅនូវ និតិវិធីរបស់ខ្លួន និង បែបបទហិរញ្ញវត្ថុ សំរាប់មូលនិធិអាស៊ាន ក្នុងការត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន ដើម្បីកំណត់ជាពិសេសការចូលរួមហិរញ្ញវត្ថុរបស់ភាគីទាំងអស់ទៅនឹងកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២៥
## សេចក្តីរាយការណ៍

ភាគីទាំងអស់ត្រូវបញ្ជូនទៅលេខាធិការដ្ឋាននូវរបាយការណ៍ ស្តីពីការចាត់វិធានការនានាដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះក្នុងទំរង់ឯកភាពគ្នា និងរយៈពេលដូចដែលបានកំណត់ដោយសន្និបាតភាគី ។

## មាត្រា ២៦
## ទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងផ្សេងទៀត

បទបញ្ញត្តិទាំងឡាយរបស់កិច្ចព្រមព្រៀងនេះ នឹងពុំធ្វើអោយប្រែប្រួលដល់សិទ្ធិ និងកាតព្វកិច្ចនានា របស់ភាគីទាំងឡាយ ចំពោះសិទ្ធិសញ្ញា អនុសញ្ញា រឺកិច្ចព្រមព្រៀងដែលមានស្រាប់ដែលភាគីទាំងនោះជាសមាជិក ។

## មាត្រា ២៧

ជម្លោះនានារវាងភាគីទាំងអស់ ទៅតាមការបកស្រាយ រឺការអនុវត្តន៍ រឺការប្រតិបត្តិតាមកិច្ចព្រមព្រៀង រឺពិធីសារនានាដែលមាននោះត្រូវបានដោះស្រាយដោយការសម្រុះសម្រួលតាមរយៈកិច្ចពិគ្រោះយោបល់ រឺការចរចាគ្នា ។

## ផ្នែក VI អវសានបញ្ញត្តិ

### មាត្រា ២៨
### ការផ្តល់សច្ចានុម័ត ការទទួលស្គាល់ ការយល់ព្រម និងការចូលរួម

កិច្ចព្រមព្រៀងនេះនឹងត្រូវជាប្រធានបទសំរាប់ការផ្តល់សច្ចានុម័ត ការទទួលស្គាល់ ការយល់ព្រម ការចូលរួមដោយប្រទេសជាសមាជិក ។ កិច្ចព្រមព្រៀងនេះនឹងត្រូវបើកចំហរសំរាប់ការចូលរួមចាប់ពីថ្ងៃបន្ទាប់ពីកិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខារួច ។ ឯកសារនៃការផ្តល់សច្ចានុម័ត ការទទួលស្គាល់ ការយល់ព្រម រឺការចូលរួម នឹងត្រូវដំកល់ទុកនៅទីកន្លែងដំកល់ឯកសារ ។

### មាត្រា ២៩
### ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានក្នុងរយៈពេល ៦០ថ្ងៃបន្ទាប់ពីការដាក់ឯកសារធ្វើសច្ចានុម័តការទទួលស្គាល់ ការយល់ព្រម និងការចូលរួមបានចំនួន ៦ច្បាប់ ។

២- សំរាប់ប្រទេសជាសមាជិកដែលផ្តល់សច្ចាអនុមត័ ទទួលស្គាល់ យល់ព្រម រឺចូលរួមទៅនឹងកិច្ចព្រមព្រៀងនេះ បន្ទាប់ពីការដាក់ឯកសារខាងលើបានចំនួន ៦ ច្បាប់ កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមានក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីការដាក់ឯកសារពីប្រទេសជាសមាជិកទាំងនោះ ។

### មាត្រា ៣០
### ការបំរុងទុក

ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀតដោយកិច្ចព្រមព្រៀងនេះទេនោះ មិនមានការបំរុងទុកណាមួយដែលត្រូវបានធ្វើឡើងចំពោះកិច្ចព្រមព្រៀងនេះទេ ។

### មាត្រា ៣១
### ការិយាល័យទទួលឯកសារ

កិច្ចព្រមព្រៀងនេះនឹងត្រូវបានដំកល់ទុកនៅអគ្គលេខាធិការអាស៊ាន ហើយនឹងត្រូវផ្តល់អោយយ៉ាងរហ័សទៅប្រទេសនីមួយៗជាសមាជិកនូវឯកសារថតចំលងត្រឹមត្រូវទាំងនោះ ។

## មាត្រា ៣២
## អត្ថបទដើម

កិច្ចព្រមព្រៀងនេះត្រូវធ្វើឡើងជាភាសារអង់គ្លេស និងត្រូវចាត់ទុកថាជាអត្ថបទដើម ។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលបានទទួលការអនុញ្ញាតដោយត្រឹមត្រូវពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០០២ ។

ដោយរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេ ដារូសាឡឹម

ឯកឧត្តម Dato Seri Paduka បណ្ឌិត Awang Haji Ahmadbin Haji Jumat
រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍

ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តម Keo Puth Reasmey
ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី

ដោយរាជរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

លោកជំទាវ Liana Bratasida
អនុរដ្ឋមន្ត្រី

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ឯកឧត្តម បណ្ឌិតសាស្ត្រាចារ្យ Bountiem Phissamay
រដ្ឋមន្ត្រីប្រចាំការិយាល័យនាយករដ្ឋមន្ត្រី
ប្រធានស្ថាប័នវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន

ដោយរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី

ឯកឧត្តម Dato Seri Law Hieng Ding
រដ្ឋមន្ត្រីក្រសួង វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងបរិស្ថាន

ដោយរដ្ឋាភិបាលនៃសហភាព មីយ៉ាន់ម៉ា

ឯកឧត្តម U Thane Myint
លេខាធិការ គណៈកម្មាធិការជាតិផ្នែកបរិស្ថាន
អគ្គនាយកនៃក្រសួងការបរទេស

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន

ឯកឧត្តម Heherson T. Alvarez
លេខាធិការ នាយកដ្ឋានបរិស្ថាន និងធនធានធម្មជាតិ

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសឹង្ហបុរី

ឯកឧត្តម Lim Swee Say
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់

ឯកឧត្តម Chaisiri Anamarn
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃឡង់ប្រចាំប្រទេសម៉ាឡេស៊ី

ដោយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

ឯកឧត្តម Nguyen Van Dang
អនុរដ្ឋមន្ត្រី ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# ឧបសម្ព័ន្ធ

## លក្ខខណ្ឌយោងរបស់មជ្ឈមណ្ឌល សំរបសំរួលអាស៊ាន សំរាប់ត្រួតពិនិត្យការបំពុលដោយផ្សែងអ័ព្ទឆ្លងកាត់ព្រំដែន

មជ្ឈមណ្ឌលអាស៊ានត្រូវ :

១- បង្កើត និងថែរក្សាការទាក់ទងជាប្រចាំ ជាមួយនិងមជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិនិមួយៗ ចំពោះទិន្នន័យដែលបានមកពីរូបភាពផ្កាយរណប និងការអង្កេតមើលដោយឧតុនិយម ដែលទាក់ទងទៅនឹង :
ក-ភ្លើងឆេះព្រៃនិង/រឺដី
ខ-លក្ខណ្ឌបរិស្ថានដែលនាំអោយមានអគ្គិភ័យទាំងនេះនិង
គ-គុណភាពខ្យល់ និងកំរិតនៃការបំពុលជាពិសេសផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនេះ ។

២- ទទួល ពីមជ្ឈមណ្ឌលអង្កេតតាមដានថ្នាក់ជាតិនីមួយៗ រឺអង្គភាពទំនាក់ទំនងនូវទិន្នន័យខាងលើ ដោយធ្វើការបញ្ចូលគ្នា វិភាគ និងរៀបចំបញ្ចូលទិន្នន័យទាំងនេះ ទៅក្នុងទ្រង់ទ្រាយដែលមានលក្ខណៈងាយយល់ និងងាយប្រើប្រាស់ ។

៣- បង្កលក្ខណៈងាយស្រួលដល់កិច្ចសហការ និងការសំរបសំរួលក្នុងចំណោមភាគីទាំងអស់ដើម្បីបង្កើនការរៀបចំទុកជាមុនសំរាប់ឆ្លើយតបទៅនឹង ភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនេះ ។

៤- បង្កលក្ខណៈងាយស្រួលដល់ការសំរបសំរួលក្នុងចំណោមភាគីទាំងអស់ រដ្ឋដ៏ទៃទៀតនិងអង្គការនានាដែលពាក់ពន្ធ័ក្នុងការចាត់វិធានការដ៏មានប្រសិទ្ធិភាព ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនេះ ។

៥- បង្កើត និងថែរក្សាបញ្ជីអ្នកឯកទេសដែលមកពីខាងក្រៅ និងខាងក្នុងតំបន់អាស៊ានដែលអ្នកទាំងនោះអាចធ្វើការងារបានក្នុងការចាត់វិធានការដើម្បីកាត់បន្ថយនូវផលប៉ះពាល់ពីភ្លើងឆេះព្រៃនិង/រឺដី រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គីភ័យទាំងនេះ និងរៀបចំបញ្ជីឈ្មោះដែលមាននេះអោយទៅភាគីទាំងអស់ ។

៦- បង្កើតអោយមាន និងថែរក្សាបញ្ជីឈ្មោះគ្រឿងបរិក្ខារ និងឧករណ៍បច្ចេកទេសដែលបានមកពីខាងក្រៅនិងក្នុងតំបន់អាស៊ាន ដែលគ្រឿងឧតបរណ៍ទាំងនេះអាចត្រូវបានគេប្រើក្នុងពេលចាត់វិធានការ ដើម្បីកាត់

បន្ថយនូវផលប៉ះពាល់ពីភ្លើងឆេះព្រៃនិង/រឺផ្សែង ការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះ និងរៀបចំបញ្ជីទាំងនេះអោយទៅភាគីទាំងអស់ ។

៧- បង្កើតអោយមាន និងថែរក្សាបញ្ជីឈ្មោះអ្នកឯកទេសដែលមកពីខាងក្រៅនិងក្នុងតំបន់អាស៊ាន សំរាប់គោលបំណងនៃការបណ្តុះបណ្តាល អប់រំ និងការធ្វើយុទ្ធនាការដើម្បីលើកកំពស់ការយល់ដឹង និងរៀបចំបញ្ជីឈ្មោះដែលមានអោយទៅភាគីទាំងអស់ ។

៨- បង្កើត និងថែរក្សា ការទំនាក់ទំនងជាមួយនិងប្រទេស និងអង្គការផ្តល់ជំនួយនានាសំរាប់យកមកប្រើប្រាស់ជាធនធានថវិកា និងធនធានផ្សេងទៀតដែលចាំបាច់ ដើម្បីទប់ស្កាត់ និងកាត់បន្ថយភ្លើងឆេះព្រៃនិង/រឺផ្សែង រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះ និងការរៀបចំទុកជាមុនរបស់ភាគីទាំងអស់ រួមទាំងសមត្ថភាពពន្លត់អគ្គិភ័យ

៩- បង្កើតនិងថែរក្សានូវបញ្ជីឈ្មោះអ្នកផ្តល់ជំនួយទាំងនេះ និងរៀបចំបញ្ជីឈ្មោះដែលមានទៅភាគីទាំងអស់ ។

១០- ឆ្លើយតបទៅនឹងសំណើសំរាប់ រឺផ្តល់ការជួយសង្គ្រោះទៅក្នុងគ្រាដែលមានភ្លើងឆេះព្រៃនិង/រឺផ្សែង រឺការបំពុលដោយផ្សែងអ័ព្ទដែលកើតចេញពីអគ្គិភ័យទាំងនេះដោយ :
ក-ធ្វើការបញ្ជូនអោយបានឆាប់រហ័សនូវសំណើសំរាប់ជួយសង្គ្រោះទៅប្រទេសនិងអង្គការនានានិង
ខ-ធ្វើការសំរបសំរួល ជំនួយសង្គ្រោះទាំងនេះ ប្រសិនបើមានសំណើពីភាគីដែលស្នើសុំ រឺផ្តល់ដោយភាគីដែលជួយសង្គ្រោះ ។

១១- បង្កើតអោយមាន និងថែរក្សានូវប្រពន្ធ័បញ្ជូនពត៌មានសំរាប់ការផ្លាស់ប្តូរ ពត៌មានដែលទាក់ទងដូចជាអ្នកឯកទេស បច្ចេកវិទ្យា វិធីសាស្ត្រ និងមុខជំនាញវិជ្ជាជីវៈ និងរៀបចំប្រពន្ធ័ដែលមាននេះ ក្នុងទំរង់មួយងាយស្រួល ផ្ញើរទៅគ្រប់ភាគីទាំងអស់ ។

១២- ចងក្រង និងផ្សព្វផ្សាយទៅភាគីទាំងអស់ នូវពត៌មានដែលពាក់ពន្ធ័ទៅនឹងបទពិសោធន៍ និងពត៌មានដែលមានសារៈប្រយោជន៍ផ្សេងទៀត ទាក់ទងនិងការប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះ ។

១៣- ជួយដល់ភាគីទាំងអស់នៅក្នុងការរៀបចំនូវទំរង់ការគំរូបទដ្ឋានសំរាប់ប្រតិបត្តិការ ។